# ការសម្ភាសរបស់បងប្រុស ជាតិ សុភក្រ្ត័

កះ អ្នកធ្វើការសម្ភាស សួន សុខលី ខះ អ្នកដែលត្រូវបានគេសម្ភាស ជាតិ សុភក្រ្ត័

កះ ជម្រាបសួរបង! ជាដំបងខ្ញុំសូមថ្លែងអំណរគុណដល់បងដែលអោយខ្ញុំធ្វើការសម្ភាសជីវប្រវត្តិរបស់ បង។ ហើយការសម្ភាសនេះគឺធ្វើឡើងដោយសារសកលវិទ្យាល័យ BYU ហើយដោយសារតែសកលវិទ្យាល័យនឹងចង់ថែរក្សាជីវប្រវត្តិជីដូនជីតារបស់បងប្រុសហើយទុក្ខអោយកូនចៅជំនាន់ក្រោយរបស់ បងមើល ហើយបន្ទាប់ពីការសម្ភាសនេះរួចហើយតើខ្ញុំអាចសុំដាក់ការសម្ភាសមួយហ្នឹងនៅក្នុង ប្រព័ន្ធវីបផ្សាយថា WWW. Cambodianoralhistories.byu.edu បានដែរឬទេបងបងប្រុស? បានដែលទេបង ហាហា?

ខះ បានតើ។

កះ ចាំ! ហើយចឹងខ្ញុំជាអ្នកសម្ភាសបងគឺមានឈ្មោះថា សួន សុខលី ហើយការសម្ភាសនេះគឺធ្វើឡើងនៅ ថ្ងៃទីអើ ២៩ ខែ០១ ឆ្នាំ២០១៨។ ដែលមានទីកន្លែងនៅអើ ភូមិបួន សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ។ ហើយចឹងខ្ញុំចង់សួរបងប្រុសថា តើបងប្រុសមានឈ្មោះអីគេដែរ?

ខះ ខ្ញុំមានឈ្មោះថា ជាតិ សុភក្រ្ត័។

កះ ជាតិ សុភក្រ្ត័។ ចឹងបងឈ្មោះបងនៅក្នុងអត្តសញ្ញាណប័ណ្ណបងអីគឺដូចគ្នាមែនទេបង?

ខះ អើខ្ញុំអត់មានអត្តសញ្ញាណប័ណ្ណអីទេ តែឈ្មោះហ្នឹងនិងនាមត្រកូលហ្នឹងគឺជាឈ្មោះហ្នឹងតែម្តង។

កះ ចាំ! នាមត្រកូលតែម្តង។

ខះ ហ្នឹងហើយ។

កះ ចាំ! ហើយអើខ្ញុំចង់សួរបងទៀតថា តើបងមានឈ្មោះគេហៅក្រៅអត់?

ខះ ខ្ញុំអត់មានឈ្មោះហៅក្រៅពីហ្នឹងទេ គឺមានឈ្មោះភក្រ្ត័ហ្នឹងទទេតែម្តងតែបើសិននាមត្រកូលវីញគឺ នាមត្រកូល ជាតិ សុភក្រ្ត័ហ្នឹងតែម្តង។

កៈ ចា៎! ជាតិ សុភក្រ្ត័
ហើយចឹងខ្ញុំចង់សួរបងទៀតថាតើបងមានឈ្មោះនៅកាលពីក្មេងអីមានអត់បង?
កាលពីក្មេងគេហៅម៉េចអីចឹងណា៎?

ខៈ អ៎! គេហៅថា អាជ្រឹង។

កៈ អាច្រឹង ហាហា វាកំប្លែង។

ខៈ បាទ!

កៈ ចា៎! ហើយអើខ្ញុំចង់សួរបងប្រុសទៀតថា តើបងមានអាយុប៉ុន្មានដែរនៅក្នុងឆ្នាំហ្នឹង?

ខៈ អើខ្ញុំអាយុចូលសាមប្រាំពីរហើយ។

កៈ សាមប្រាំពីរហើយ។

ខៈ បាទ! ហ្នឹងហើយ។

កៈ ចា៎! ចឹងបងចាំអំពីអើថ្ងៃខែឆ្នាំកំណើតរបស់បងអត់ ថាកើតនៅឆ្នាំណាខែណាដែរបង?

ខៈ ខ្ញុំកើតនៅខែ បី ថ្ងៃប្រាំបី។

កៈ នៅខែ បី ថ្ងៃប្រាំបី ឆ្នាំអីគេដែរបង?

ខៈ បាទគឺឆ្នាំរការ។

កៈ ឆ្នាំរការ។ ឆ្នាំចង់និយាយថា ពីរពាន់ប៉ុន្មានអីហ្នឹងណា?

ខៈ អើប៉ែត ចូលប៉ែតមួយហើយហ្នឹង។

កៈ ចូលប៉ែតមួយ។ ចឹងមានន័យថានៅឆ្នាំមួយពាន់ប្រាំបួនរយប៉ែតមួយ?

ខៈ ហ្នឹងហើយ។

កៈ ហើយខ្ញុំចង់សួរបងថាតើទីកន្លែកំណើតរបស់បងណា
តើបងកើតនៅស្រុកណាខេត្តណា ឃុំណាដែរ?

ខៈ នៅភ្នំពេញ។

កៈ នៅភ្នំពេញ។

ខ៖ ហ្នឹងហើយ។

ក៖ អើយុំអី សង្កាត់អីគេដែរបង?

ខ៖ ខ្ញុំអត់សូវដឹងប្រវត្តិទេ តែបើដឹង ដឹងនៅមួយដុំក្បាលថ្នល់ហ្នឹង។ គេហៅថាក្បាលថ្នល់ប៉ុន្តែមិនដឹងគេ ហៅភូមិអី ផ្លូវអីហ្នឹងអត់ដឹងទេ ព្រោះចេញពីផ្ទះតាំងតែពីអាយុប្រាំបួនឆ្នាំមកម៉េស។

ក៖ ចាំ! ចឹងបងកើតនៅក្បាលថ្នល់ មែនកើតនៅពេទ្យបាយ័ន្តទេ ហាហា។

ខ៖ អត់ដឹងថាពេទ្យបាយ័ន្តហ្នឹងគេបែរមុខទៅខាងណាផងហ្នឹង។

ក៖ ចាំ! ហើយចឹងខ្ញុំចង់សួរបងទៀតថាតើបងប្រុសមានបងប្អូនជំនួនប៉ុន្មាននាក់ដែរ?

ខ៖ ខ្ញុំមានបងប្អូនចំនួនប្រាំបីរនាក់។

ក៖ ប្រាំបីរនាក់។

ខ៖ ហ្នឹងហើយ។

ក៖ ចាំ!
ចឹងបងអាចរៀបរាប់ឈ្មោះពីកូនបងរហូតដល់កូនពៅទាំងប្រាំបីនាក់ហ្នឹងបន្តិចបានទេបង?

ខ៖ អើ វណ្ណសុភា។

ក៖ វណ្ណ សុភា។

ខ៖ អើជាតិ សុភក្រ្ត័។

ក៖ ជាតិ សុភក្រ្ត័។

ខ៖ អើ ដុត ស្រីណោត។

ក៖ ដុត ស្រីណោត ទៀតបង។

ខ៖ ជាតិ ស្រីលក្ខ័ អរអីគេ ជាតិ វល្ល័ក្ខ។

ក៖ ជាតិ វល្ល័ក្ខ។

ខ៖ ដុត ស្រីណោត។

កៈ ដុត ស្រីណោត។

ខៈ ដុត ទោ។

កៈ ដុត ទោ។

ខៈ ដុត ទី។

កៈ ដុត ទី។

ខៈ ដុត ចាន់ទីហ្នឹងណា៎ ហើយដុតទោល។

កៈ ដុត ទោល។

ខៈ ហើយនិងដុត ស្រីណោត។

កៈ ដុត ស្រីណោត។

គៈ ហើយអាដុតស្រីណោតច្រើនដងម៉េស។

កៈ គ្រប់អស់ហើយតើអីបងប្រាំបីអ្នកអី?

ខៈ អើដុត ស្រីណោតមិនចុងក្រោយគេដុត ស្រីវង្សអី?

គៈ អើមីណោត ហើយបានមីវង្ស។

ខៈ អើដុត ស្រីណោតហើយ បានដុតទោល។

គៈ ហ្ហែ៎ ដុតអីដុតរហូតចឹង។

កៈ ហាហា! ចា៎!

ខៈ អស់ហើយប្រាំបីនាក់ហ្នឹង។

កៈ ចា៎! អរគុណបង! ហាហា! ចឹងខ្ញុំចង់សួរបងទៀតថា បងជាកូនទីប៉ុន្មាននៅក្នុងគ្រួសារ?

ខៈ នៅក្នុងគ្រួសារ ខ្ញុំជាកូនទីពីរ។

គៈ កូនទីមួយរយមួយម្ដែពីរ។ (ប្រពន្ធអ្នកបន្ទរពីខាងក្រោយ)

កៈ ហាហា! ចាំ! ហើយអើខ្ញុំចង់សួរបងទៀតថា
តើបងបានចងចាំអ្វីខ្លះអំពីសាច់រឿងនៅពេលដែលបង
នៅជាកូនក្មេងជាមួយនិងបងប្អូនបងណាំ?

ខៈ បើចាំសាច់រឿងថាយើង ធ្មមតាទេអ្នកក្រខ្សត់ចឹង យើងធ្លាប់ចាំប្រវត្តិថា...

គៈ ធ្លាប់រត់ស្រោតខោ។ (ប្រពន្ធគាត់និយាយលេង)

កៈ ហាហា!

ខៈ ហាហា! ស្រោតខោហ្នឹងក្មេងទេ មិនមែនមនុស្សចាស់ទេ
មនុស្សចាស់គេបើថាស្រោតខោវិញ អាហ្នឹងគេ ថាឆ្កួតសុទ្ធហើយ។

គៈ ហ្នឹងហើយស្រោតខោរត់ពេលនៅក្មេងនុ៎ះ។

ខៈ អើបើមនុស្រចាស់វិញវាឆ្កួតណាំ រត់ស្រោតខោ។
អើបើនិយាយអោយចំទៅភាគច្រើនទៅគឺយើងចាំ ត្រង់ថា
ឪពុកយើងហ្នឹងធ្លាប់លីសែងឥវ៉ាន់ លីអីចឹង លីសែងឥវ៉ាន់ អោយគេនៅក្បាលថ្នាល់ជិតផ្សារ
ច្បារអំពៅយើងនេះ។
រកស៊ីចិញ្ចឹមគ្រួសារយើងទាំងប៉ុន្មាននៅពេលដែលយើងនៅតូចៗហ្នឹង ព្រោះ
ពេលហ្នឹងយើងមិនទាន់ចេះរកស៊ីចិញ្ចឹមគ្រួសារ កាលហ្នឹងខ្ញុំទើបតែអាយុបានប្រាំពីរ
ប្រាំបីឆ្នាំ នាំឆ្នាំហ្នឹងចេះដើររកលុយចិញ្ចឹមឪពុកម្តាយវិញ។
ហើយពេលខ្ញុំឃ្លាតពីផ្ទះគឺនៅពេលខ្ញុំមានអាយុប្រាំ បួនឆ្នាំហ្នឹងម៉ង។
ខ្ញុំចេញពីផ្ទះអាយុប្រាំបួនឆ្នាំ ទើបតែចូលផ្ទះវិញនៅអាយុដប់បីដប់បួននេះទេពេល
ខ្ញុំត្រលប់មកនៅភ្នំពេញវិញណា គឺត្រលប់ចូលមកនៅបឹងត្របែកយើងនេះវិញ
គឺនៅក្នុងឆ្នាំ២០១៤ ២០១៥ហ្នឹងម៉ង។

កៈ ចាំបង!

ខៈ គឺខ្ញុំចូលមកនៅបឹងត្របែកហ្នឹង។

កៈ ចាំ! អរគុណបងចឹង។ ខ្ញុំចង់សួរបងប្រុសទៀតថានៅពេលដែលបងប្រុសនៅក្មេងណាំ
តើបងចូល ចិត្តធ្វើអីគេខ្លះសម្រាប់ អើបងប្អូនបងដែរចឹងណាំ?

ខៈ ដើរបាចត្រី បេះផ្កាកំផ្លោកលក់អី អោយបងប្អូនបេះផ្កាកំផ្លោកលក់អីចឹង។

កះ ហាហា! អ់! ចាំ! សប្បាយតើបង។ ចាំ! ហើយចឹងខ្ញុំចង់សួរបងទៀតថា...

ខះ អាទីៗឯងដើរទៅយកគោជល់ពូពៅអោយអញមួយមើល
គោជល់ហើយនិងទឹកកកមួយកែវមកទៅ។

កះ ហើយខ្ញុំចង់សួរបងទៀតថានៅពេលនេះតើពួកគាត់រស់នៅកន្លែងណាដែរ?
ពួកគាត់នៅ...

ខះ អត់ដឹងទេ តែបើដុត ទោលវិញរស់នៅ ខេត្តកោះកុង។

កះ គាត់រៀបការប្រពន្ធនៅហ្នឹងអីបង?

ខះ អត់ដឹងដែរ។ ដឹងការមិនការទេ ព្រោះអីយើងបែកគ្នាតាំងពីក្មេងមកម៉េស
អាយុប្រាំបួនឆ្នាំមកម៉េស។

កះ ចាំ! ហើយចឹងខ្ញុំចង់សួរបងទៀតថាឪពុកម្ដាយរបស់បងណាមានឈ្មោះអីគេដែរបង?

ខះ អើម្ដាយខ្ញុំឈ្មោះ ជាតិប៊ុន ថា។

កះ ចាំ!

ខះ ឪពុកឈ្មោះ ដុត វ៉ាន់។

កះ ចាំ!
ចឹងបងមានចាំពីថ្ងៃខែឆ្នាំកំណើតពួកគាត់អត់បងថាពួកគាត់កើតនៅថ្ងៃណាខែណា?

ខះ ខ្ញុំអត់ដឹងទេព្រោះយើង អត់បានសួរនាំរឿងគាត់កើតខែណា ឬក៏ខែឆ្នាំអីទេព្រោះរឿង
ហ្នឹងមិនអាច និយាយបានទេ យាយកើតបាន។

កះ ចាំ! ហើយចុះឪពុកបង អត់ដែរអី?

ខះ អើអត់ទាំងអស់ ឪពុកម្ដាយគឺអត់មានចាំថ្ងៃខែឆ្នាំកំណើតទេ
តែចំពោះឪពុកម្ដាយយើងអាចចាំថ្ងៃ ខែឆ្នាំកំណើតយើង។

កះ ចាំ!

ខះ អាសែអើយយកលុយនេះលុយនែក ប៉ុន្មាន?

គៈ គាត់ស្លាប់អត់លើទេ។

ខៈ អញស្លរគាត់ប៉ុន្មាន?

កៈ អើយហើយចឹងខ្ញុំចង់សួរបងទៀតថាពួកគាត់ណាកើតនៅកន្លែងណាដែរ?

ខៈ បាទ?

កៈ ពួកគាត់ណាលកើតនៅកន្លែងណាដែរ?

ខៈ នៅភ្នំពេញទាំងអស់។

កៈ នៅភ្នំពេញទាំងអស់ម៉ងនុះ?

ខៈ បាទ!

កៈ ចាំ! ចឹងអត់មានស្រុកកំណើតអីដែលត្រូវទៅទេអីបង?

ខៈ អុំ! ធ្លាប់ទៅ ធ្លាប់ទៅនៅក្នុងពេលថ្ងៃបុណ្យទាន យាយស្លាប់អី។

កៈ ចាំ! នៅស្រុកណាខេត្តណាដែរបង?

ខៈ នៅខេត្តអើស្អាង។

កៈ នៅស្អាង។

ខៈ ស្រុកស្អាង ខេត្តកណ្តាល។

កៈ ចាំ! ស្រុកស្អាង ខេត្តកណ្តាល។ ចាំ! ចុះបងមានដឹងថាឆ្នាំខ្មែរណា
ដូចជាម៉ាករបស់បងណាគាត់កើត នៅឆ្នាំ ម្សាញ់ ជូតអី បងមានដឹងទេ?

ខៈ នៅឆ្នាំរការដូចគ្នា អោយដឹងតែត្រឹមម៉ែខ្ញុំហើយនិងខ្ញុំហ្នឹងកើតឆ្នាំរការដូចគ្នា។

កៈ ចាំ! ហើយចុះឪពុកបងវិញ?

ខៈ ឪពុកខ្ញុំជាមួយនិងប្អូនខ្ញុំបន្ទាប់ពីស្រី វង្ស អុំ! ស្រីណោតនេះ ឆ្នាំមមែដូចគ្នា។

កៈ ឆ្នាំមមែអី?

ខៈ ហ្នឹងហើយ។

កៈ ចាំ! ចឹងខ្ញុំចង់សួរបងទៀតថាតើបងចាំថាឪពុករបស់បងណាំ
តើគាត់បានធ្វើអ្វីខ្លះសម្រាប់ចិញ្ចឹម ជីវិតរបស់គាត់ហើយនិងក្រុមគ្រួសារណាំ?

ខៈ គឺលីសែង។

កៈ លីសែងអីគេដែរបង?

ខៈ លីសែងឥវ៉ាន់អីទូទៅ ដូចជាបន្លែអើ បន្លែបន្លុកអីចឹង
ឈើអីៗដែលគេហៅទៅសែងលីអីចឹងហ្នឹងណា គាត់ហ្នឹងចេះតែប្រឹងទៅហើយ
រហូតដល់គាត់គ្រាំក្នុងរហូតដល់គាត់ស្លាប់បាត់បង់ជីវិត។

កៈ ចាំ!

ខៈ ឪពុកណាំ ឥឡូវនៅសល់តែម្ដាយមួយគាត់ធូន់ត្រចៀក គាត់ចេះទាយអោយគេទៀត។

កៈ ចាំ! ចឹងគាត់។

ខៈ គាត់ទាញបៀរចិញ្ចឹមជីវិត ចិញ្ចឹមកូនយើងតូចនេះ
ពេលដែលយើងធំៗមនុស្សក្បាលកញ្ចាស់នេះ ចេញ ពីគាត់ទៅនេះ
គាត់តស៊ូចិញ្ចឹមកូនដេកវាល ផ្ទះសម្បែងឥឡូវសព្វថ្ងៃនេះ រហូតមកជួលគេនៅទៀត
គ្មានលុយគ្មានកាក់អីទេសូម្បីតែគ្រួសារខ្ញុំនេះ សឹងថានេះហ្នឹងក៏ជួលផ្ទះនៅដែរ។
មួយខែប្រាំពីរម៉ឺន ហ្នឹងមិនសឹងតែមានលុយអោយគេផង នុះម្ដាយខ្ញុំគាត់នៅខាងនុះ។

កៈ ចាំ! ហើយម្ដាយរបស់បងនៅរស់ដល់សព្វថ្ងៃ?

ខៈ នៅរស់រហូតទល់តែឥឡូវ។

កៈ
ហើយចឹងអើខ្ញុំចង់សួរបងទៀតថាម្ដាយរបស់បងមិញគាត់ប្រកបមុខរបចិញ្ចឹមជីវិតដោយកា
រធ្វើ គ្រូទាញមែនទេបង?

ខៈ ហ្នឹងហើយ។

កៈ ចាំ! ចុះខ្ញុំចង់សួរបងទៀតថា
តើឪពុកម្ដាយរបស់បងណាមានដែលធ្លាប់និយាយរឿងរបស់ពួកគាត់
នៅក្មេងៗប្រាប់បងអត់?

ខ៖ អត់និយាយផងគាត់ខ្លាចយើងពិបាក
ព្រោះខ្លាចយើងនៅក្នុងនាំជាកូនបងកូនអីយើងវាពិបាក ណាស់។
ពេលស្តាប់រឿងគាត់និទាន អើមួយដងៗមកណា និទានរឿងប្រវត្តិរបស់គាត់
ការគាត់បានគ្នា ហ្នឹងយើងក៏អត់ដឹងថាគាត់ហ្នឹងម៉េចអីម៉េចដែរ។
គាត់អត់មានបាននិយាយអីប្រាប់ពីប្រវត្តិយើង ទេ។

ក៖ ចាំ! អរគុណបង។ ចឹងអើខ្ញុំចង់សួរបងប្រុសទៀតថា
តើនៅអើបងមានចាំឈ្មោះជីដូនជីតាខាង ឪពុករបស់បងទេបង?

ខ៖ អត់! អត់ស្គាល់ទាំងអស់។

ក៖ ចុះខាងម្តាយវិញ អត់ដែរអីបង?

ខ៖ អត់ដែរ! អត់ទាំងអស់។ ហើយក៏អត់បានដែលឃើញមុខឃើញមាត់ម៉េចផង។

ក៖ ចាំ! ចុះបងមានថាអើជីដូនជីតារបស់បងណា
ភាគច្រើនពួកគាត់រស់នៅខេត្តឬក៏រស់នៅភ្នំពេញ? ហើយខេត្តណាដែរអីចឹងណា?

ខ៖ យាយខ្ញុំនៅខេត្តកណ្តាលហ្នឹងម៉ង។ ចាំតែខេត្តទេ
តែបើជីតាយាយខ្ញុំហ្នឹងក៏មិនដឹងថាគាត់ នៅខេត្ត ណាដែរ។
តែបើថាភាគច្រើនខ្ញុំសង្ឃឹមថាពួកគាត់ហ្នឹងនៅខេត្តជាមួយគ្នាហើយ។ ធ្លាប់ដឹងថាយាយខ្ញុំ
ធ្លាប់និយាយប្រវត្តិប្រាប់ពីឪពុកម្តាយខ្ញុំ កាលគាត់នៅពីក្មេងណាំ។

ក៖ ចាំ! ម៉េចដែរបង?

ខ៖
គាត់និយាយថាកាលពីជំនាន់ប៉ុលពតណាពួកឯងសំណាងហើយដែលចេះកើតផុតជំនាន់ប៉ុលពត តែបើសិនជាកើតទាន់វិញណាំ
ពួកឯងត្រូវគេអាករហ្នឹងធាងត្នោតហើយព្រោះអញពិបាកណាស់ បាយ
អង្ករអីមិនដឹងនៅណា បាយទឹកអីមិនដឹងនៅណា ធ្វើការទាំងយប់ទាំងថ្ងៃ ក្រោមភ្លៀង
ក្រោម ខ្យល់ ស្លៀកខ្យល់ដណ្តប់មេឃ ដូចថាឃ្លានមិនដឹងចំណីអីនៅណា ទឹកអីនៅណា
តែធ្វើអីតិចហ្នឹងគេ អោយ ស៊ីចំណីដូចជាសត្វចឹង។ ទើបបានចិញ្ចឹមជីវិតនិងរស់តស៊ូ
ត្រូវសម្លឹងឃើញស្អី ហូបហ្នឹងហូបបានហូប បើហូបមិនបានគឺចប់ហើយ។

កៈ ចាំ!
ចឹងអើខ្ញុំចង់សួរបងទៀតថាតើក្រុមគ្រួសារបងសព្វថ្ងៃហ្នឹងពួកគាត់រស់នៅខេត្តណាខ្លះដែរ?

ខៈ អើខ្ញុំអត់ដឹងផង បើធ្លាប់បែកគ្នាដូចជាអានេះអីនៅម្ដុំដៃថៃ ម្ដុំម៉ាឡេអីឯណានុះ។

កៈ អំ! គាត់នៅម្ដុំដីថៃ។

ខៈ បាទដល់ពេលមកវិញធ្លាក់ខ្លួនចឹងនេះតើមានស្អីទេ
ភាគច្រើនដល់តែឈឺចឹងពឹងលើម្ដាយទាយបៀរ ចិញ្ចឹមជីវិតទៀត។
ស៊ីចុកហូបចុកអីជាមួយគាត់ យើងឯនេះវិញឆ្លៀតពេលរើសអេតចាយរើសអីទៅ
ចិញ្ចឹមកូនចិញ្ចឹមអីទៅទាំងបួននាក់ហ្នឹង បីបួននាក់ហ្នឹង។

កៈ ចាំ! ចុះអាឡូវហ្នឹងខ្ញុំចង់សួរបងថាពួកគាត់នៅជុំគ្នានៅក្នុងភូមិបួនហ្នឹងទាំងអស់?

ខៈ គ្រួសារខ្ញុំជុំគ្នាទាំងអស់ហ្នឹង។

កៈ ចាំ! ហើយអើខ្ញុំចង់សួរបងទៀតថា
តើបងមានសាច់ញាតិដ៏ទៃទៀតដែលរស់នៅប្រទេសក្រៅដូចជា
ជីដូនមួយអីណាមានទេបង?

ខៈ អត់មានទេ អត់ទេ។

កៈ ចាំ!

ខៈ ហ្នឹងហើយ។

កៈ ចឹងខ្ញុំចង់សួរបងទៀតថា អើភរិយារបស់បងមានឈ្មោះអីដែរ?

ខៈ អើហោង ស្រីណា ហៅសែ។

កៈ ឈ្មោះហោង ស្រីណា ហៅសែ។
ចឹងអើខ្ញុំចង់សួរបងទៀតថានៅពេលដែលបងរៀបអាពាហ៍ពិពាហ៍ហ្នឹង នៅឆ្នាំណា
ខែណាដែរបង?

ខៈ អត់ទេ! អត់យក។ ខ្ញុំយកគ្នាអត់មានខាន់ស្លាទេ។

កៈ ចាំ!

ខ៖ យកគ្នាគឺអត់មានខានស្លាទេ គឺយកគ្នាតាមចិត្តចង់។

ក៖ ចិត្តស្រលាញ់។

ខ៖ ហ្នឹងហើយតាមចិត្តខ្លួនដោយខ្លួនឯងម៉ង។

ក៖ ចាំ! ហើយខ្ញុំចង់សួរបងទៀតថាតើការដែលបងស្រលាញ់គ្នា ដើម្បីចាប់ដៃគ្នាជាគូប្តីប្រពន្ធជាមួយ គ្នាហ្នឹង តើដឹងលឺដល់ឪពុកម្តាយសងខាងទេបង?

ខ៖ ដឹងទាំងអស់ហើយហ្នឹង។

ក៖ ចាំ! ចុះពួកគាត់មានបង្គាប់ផ្ញើជំនួនអីខ្លះៗទេបង?

ខ៖ អត់ទេ! គឺពួកគាត់បង្គាប់អោយយើងហ្នឹងចេះស្រលាញ់គ្នា។ កុំវាញកុំចេ កុំជំកុំអី តែយើងនេះ ឃ្លាត បានតែមុខគាត់ល្អ តែបើនៅក្រោយខ្នងគាត់អាចចេរបញ្ចោរវ៉ៃប្រពន្ធវ៉ៃអី ចេរប្រពន្ធចេរអីមាន មែន។ រឿងខ្ញុំហ្នឹងណា ខ្ញុំធ្លាប់វ៉ៃប្រពន្ធវ៉ៃអីក្រោយខ្នងអីមែន តែបើគាត់វិញហាមមិនអោយ វ៉ៃកូនវ៉ៃអី នៅមុខគាត់ទេឬក៏ចេរនៅមុខគាត់ទេ តែជួនកាលទៅខ្ញុំនៅបំពានមុខគាត់ហ្នឹងក៏មានដែរណាស់។ នៅខាងឪពុកម្តាយក្មេកខ្ញុំហ្នឹងណា ខាងម្តាយខ្ញុំបង្កើតហ្នឹងក៏ខ្ញុំវ៉ៃប្រពន្ធចេរប្រពន្ធចឹងដែរ។ តែ ពេលដែលយើងដឹងខ្លួនចឹងទៅ ទើបបានដឹងថាយើងហ្នឹងម៉េចបានជាធ្វើចឹង យើងពិចារណាមើល ថាមនុស្សយើងក្បាលកញ្ចាស់ហើយ ហើយហេតុអីបានជាមិនគិតអោយបានវែងឆ្ងាយ ឈ្លោះគ្នាទាំង មុខ ម៉ែយើងបង្កើតផង មុខម៉ែគេឯនុះ ម៉ែក្មេកគេនុះផង តែដល់ពេលយើងឃ្លាតពីម៉ែគេឯនេះ ប្រហែលពីរបីឆ្នាំហ្នឹងជាង។ មិនដឹងមុខមាត់របៀបម៉េចទេឥឡូវ ទើបតែបានត្រឹម ម៉ានឹកឃើញដល់ គាត់ហ្នឹង។

ក៖ ចាំ!

ខ៖ តែដល់តែពេលចង់ជួបមុខគាត់មិនដឹងគាត់នៅឯណាផងហ្នឹង។ អត់ជួបគាត់ផងហ្នឹង ចឹងយើង ដូចជាសត្វមួយដែលគ្មានសាច់ញាតិម៉ងហ្នឹងណាំ តែលគោលដូចអាលក(សត្វ)ម៉ងហ្នឹងណាំ។

ក៖ ចាំ! មិនអីទេបង។ ហើយចឹងខ្ញុំចង់សួរបងថា ពេលដែល...

គ៖ ហ្ហ៎!

ខ៖ អានេះរឿងឯងមែន គ្រួសារអញតើ។

ក៖ អត់អីទេបង បងអាចនិយាយអ្វីដែលជាអារមណ៍របស់បងណា៎
ដើម្បីអោយកូនចៅជំនាន់ក្រោយ របស់បងពួកគាត់អាចដឹង។

ក៖
ចឹងខ្ញុំចង់សួរបងទៀតថានៅពេលដែលបងបានជួបជាមួយនឹងបងស្រីគ្រាដំបូងហ្នឹងណា៎
តើបង ស្រលាញ់គ្នាដោយរបៀបម៉េចចឹងណា៎?

ខ៖ អ៎! ស្រលាញ់គ្នាដោយមនោសញ្ចេតនាវាងចិត្តស្មោះហ្នឹងម៉ងណា៎។

ក៖ ចា៎! ហើយបងជួបគា្នជាមួយគាត់នៅណាដែរ បានចាប់ដៃគ្នាជាប្តីប្រពន្ធ?

ខ៖ ជួបគ្នានៅអូរឡាំពិច នៅកន្លែងអាងទឹកអូឡាំពិចហ្នឹង។

ក៖ ចា៎! ហើយបន្ទាប់មកក៏ចាប់ផ្តើមស្រលាញ់គ្នាអីចឹងទៅ?

ខ៖ ហ្នឹងហើយបានគ្នា បានអីៗគ្នា គឺបានខ្លួនគ្នាម៉ងហ្នឹងណា
យើងក៏បានចាប់ដៃគ្នាចឹងទៅ។

ក៖ ហើយបងប្រុសស្រលាញ់បងស្រីប៉ុណ្ណា?

ខ៖ ស្មើលើសពីជីវិតទៀត។

ក៖ ចា៎! ហើយអតឡូវបងមានកូនប៉ុនន្មាននាក់ហើយ?

ខ៖ ខ្ញុំមានកូនចំនួនបួននាក់។

ក៖ ចា៎!
ខ្ញុំចង់សួបងថាតើបងធ្លាប់ធ្វើអីខ្លះនៅពេលដែលបងចាប់ដៃគូជាមួយនិងគាត់មកណា
ចង់និយាយថាធ្វើអ្វីខ្លះដើម្បីគាត់?

ខ៖ ខ្ញុំមិនអាចនិយាយបានទេ រឿងហ្នឹងពេលដែលយើងនៅជាមួយគ្នាអីហ្នឹង។

ក៖ អត់ទេបងខ្ញុំចង់មានន័យថា តើបងបានជួយអ្វីខ្លះ ដូចជាកិច្ចការនៅក្នុងផ្ទះអីចឹងណា៎?

ខ៖ គឺពេលប្រពន្ធខ្ញុំពោះធំ ខ្ញុំជួយបោកខោអាវ លាងចានអីចឹង។
នៅពេលឆ្លងទន្លេជួយបោក សារុងបោកអី បោកកាទបអី មើលកូនមើលអីទៅណា៎
ជួយកាដៀតពរ (ពរកូន) កាដៀតអីចឹង ទៅណា៎។

ក៖ ចា៎!

ខ៖ មានគ្នាមានបងប្អូនអីជួយពឹងពាក់អោយមើល អោយពរតិចតួចទៅ។
យើងទៅលាងចានទៅ ពេល យើងលាងចាន
ឆ្លៀតក្រាលកម្រាលអីអោយប្រពន្ធដេកសម្រាន លេបថ្នាំអីហ្នឹង។ ហើយខ្ញុំដើរខ្ចី លុយ គេ
ជូនកាលគេអោយខ្ចីមួយដងដប់មឺនអីចឹងរាប់គេទៅ ហើយយើងចេញរាប់
អោយគេទៅមួយថ្ងៃ មួយមឺនអីចឹងទៅកំណត់អោយគេដប់ពីរថ្ងៃអីឲ្យចឹងទៅ។

ក៖
ហើយខ្ញុំចង់សួរបងប្រុសទៀតថាតើបងប្រុសចេះសរសេរនិងចេះអានភាសាខ្មែរច្បាស់ដែរ
ទេបង?

ខ៖ អើស្ទាត់ម៉ង។

ក៖ បងចេះស្ទាត់ម៉ង?

ខ៖ ហ្នឹងហើយ។

ក៖ ចឹងខ្ញុំចង់...

ខ៖ តែថាវាអត់សូវស្អាតត្រង់សរសេរអក្សរ តែបើសិនជាយើងអានយើងអាចអានចប់បាន។

ក៖ ចា៎!

ខ៖ មិនមែនអានដាច់ទេណាស់ គ្មានគ្រូណាដែលត្រូវអានអក្សរដាច់ទេ ខ្ញុំអត់ជឿទេ
បើដុតអាចឆេះ បាន។

ក៖ ហាហា ចា៎! ត្រូវហើយ។

ខ៖ គេថាចេះ ក្រដាសត្រូវភ្លើងអាចយកដុតបានណាស់ ត្រូវទឹកអាចសើមបាន
តែបើអក្សរមិនអាចលុប បានទេ។
ចឹងបានថានៅក្នុងមនុស្សរវាងមនោសញ្ចេតណាបានទេ។ នៅក្នុងមនុស្សមួយទូទៅភាគ

ច្រើនដែលអាចមើលអក្សរដាច់ទេ។ អ្នកឯងចេះដល់កម្រឹតកំពូលណាក៏ដោយ
ក៏គ្មានមើលអក្សរត្រូវ ដាច់ដែរ។
តែបើសិនជាអាចអ្នកឯងត្រូវមើលចប់យកទៅដុតអីអាហ្នឹងខ្ញុំជឿ។ អង្គរយកទៅពន្លិច
ទឹកអីបណ្ដែតចោលពន្លិចចោល បោះចោលតាមសំរាមតាមអីអាហ្នឹងខ្ញុំជឿ។
តែបើថាអ្នកឯងភ្នែក ឡាមមែនមើលអក្សរដាច់ខ្ញុំសឹងថ្វាយបង្គំ ដាក់មួយផ្ទាំងដូចជាអក្សរ
និងសរសេរមួយអក្សរមើល ធ្វើម៉េចអោយដាច់ពីគ្នាមើល។
បើសិនជាអ្នកឯងមើលដាច់ខ្ញុំហ៊ានកោរក្បាលខ្ញុំមួយចំហៀង។ ភាគ
ច្រើនគឺអត់មានពីណាមួយត្រូវមើលដាច់ទេ ដូចជាចែឯងចឹងត្រូវទេ?

កៈ ចាំ!

ខៈ ចែឯងសួរខ្ញុំតែភ្លេចគិតអំពីចម្ងល់ហ្នឹងហើយ។ ភាគច្រើនបើខ្ញុំសួរទៅចែឯងវិញ
ចែឯងឆ្ងល់ហើយថា ម៉េចបានជាម្នាក់ៗនិយាយថាអក្សរយើងអាចអានចប់បាន
តែមិនអាចអានដាច់បានទេ។ អ្នកឯង រៀនដល់កម្រិតកំពូលណាក៏ដោយ
អ្នកឯងចេះបកប្រែភាសាអង់គ្លេសដល់កម្រិតកំពូលណាក៏ដោយ។
ទោះចុះពីលើមេឃក៏ដោយមិនមែនអ្នកឯងហ្នឹងទេវតាទេ។
សូម្បីតែទេវតាក៏មិនអាចធ្វើអោយអក្សរ ហ្នឹងដាច់បានដែរ។

កៈ ចាំ! ហាហា! ហ្នឹងហើយត្រូហើយបង។ បងឯងនិយាយត្រូវ។

ខៈ ហាហា!

កៈ ហើយខ្ញុំអរគុណច្រើនបងប្រុស។ ហើយខ្ញុំចង់សួរបងទៀតថា
តើបងចេះនិយាយភាសាអីផ្សេងក្រៅពី ភាសាខ្មែរទេ?

ខៈ អើខ្ញុំចេះបានពីរភាសាដែរ។

កៈ បងចេះពីរភាសា ភាសារអីគេដែរបង?

ខៈ ជូនណាទៅយើងចេះអើ ដំបូងយើងចេះភាសាថៃ
តែយើងភ្លេចអស់ហើយព្រោះយើងឃ្លាតជាងមួយ ម្ភៃឆ្នាំណាំ។ ដំបូងខ្ញុំចេះស្ទាត់ភាសាថៃ
តែបើភាសាអង់គ្លេសយើងក៏អាចមើលបាន តែយើងមិនអាច អាន
ជាបកប្រែជាភាសាខ្មែរបានទេ។ ជូនកាលកន្លែងណាយើងត្រូវស្ដាប់បានថាចេះ
ក៏ចេះទៅអា កន្លែងស្ដាប់បានថាមិនចេះហ្នឹងគឺអត់តែម្ដង។

កៈ ចា៎! ចឹងបងប្រុសចេះថៃនិងបងធ្លាប់ទៅរស់នៅថៃមែនទេបង?

ខៈ ធ្លាប់ទៅអើប្រាំមួយ អើប្រាំមួយខែ។

កៈ ចា៎! បងទៅធ្វើការមែន?

ខៈ ហ្នឹងហើយ។ ខ្ញុំទៅធ្វើការ ទៅដឹកតាមឡានលីសែងផ្លែឈើហ្នឹងហើយយកលុយមក អើៗឃើញអត់។

កៈ ចា៎! ចឹងខ្ញុំចង់សួរបងទៀតថា តើបងបានរៀនដល់ថ្នាក់ទីប៉ុន្មានដែរបង?

ខៈ អើបើនិយាយកម្រិតមធ្យមគឺខ្ញុំអត់ដែលបានស្គាល់សាលាទេ
គឺយើងអាចយកចំណេះវិជ្ជាខ្លួនឯង បានដូចជាក្រដាសមួយចឹង
ដូចជាយើងកាន់ក្រដាសកាសែតមួយអីចឹង យើងយកទៅសួរអ្នកស្ទាត់
ដូចជាគ្រូបង្រៀនតាមសាលាអោយអានអោយយើងស្តាប់ក្នុងពេលមួយរឿងៗហ្នឹងតែម្តង។

កៈ ចា៎! ចឹងមានន័យថាបងឆ្លាតណាស់។

ខៈ បាទ! ចឹងយើងកាន់ក្រដាសកាសែតហ្នឹងមួយ
ហើយយើងសួរនាំគេនៅក្នុងពេលតែមួយអាទិត្យទេគឺ
យើងអាចអានេះចាំយកជាអក្សរហ្នឹងមកអានវិញបាន។ នៅក្នុងទាំងដប់រឿងហ្នឹងតែម្តង។
គឺគេ អានអោយស្តាប់ជាប់មាត់តៗគ្នា ដូចៗគ្នាចឹងយើងសួរសុទ្ធតែគ្រូចឹងយើងអាចថាចេះ
នៅក្នុង ចំណេះវិជ្ជាយើងអាចយកជាកន្លែងណាដែលត្រូវជាអក្សរ អក្សរ “រ” អក្សរ “ត”
អីចឹងគឺយើងអាច យកមកដាក់នៅក្នុងខួរក្បាលយើងអោយចងចាំបាន។
ចឹងគឺមិនអាចអោយភក់លេចបានទេដូចជាគេថាផ្លូវគឺផ្លូវហើយ អក្សរ “ផ” ជើង “ល” ស្រះ “ូ”
និង “វ” អាហ្នឹងហើយដែលគេហៅថាផ្លូវណាស់ ដូចចឹងដូចជាអក្សរយើងត្រូវយក “ស”
ដាក់ស្រះ “ំ” មានន័យថា “សំ ” ណាស់។ ភាគច្រើនគឺមានអក្សរ “ស”នាំមុខគេហ្នឹង។
បើសុំគឺសុំទោសហ្នឹងហើយ ភាគច្រើនអក្សរ “ស” គឺដឹងតែនាំមុខគេហើយ។

កៈ ចា៎បង!

ខៈ បានថាចម្ងល់វាអស់ត្រឹមហ្នឹង។ វាអត់មានអីដែលខ្ញុំត្រូវឆ្លើយទៀតទេ
អស់ពាក្យឆ្លើយតបហើយ។

កៈ ចាំ! អរគុណបង
ចឹងខ្ញុំចង់សួរបងទៀតថាបងមានមិត្តភក្តិដែលធំឡើងស្និតស្នាលជាមួយគ្នាអត់ បង?

ខៈ មានតែតើ។

កៈ គាត់មានឈ្មោះអីគេដែរ?

ខៈ អើឈ្មោះដូចគ្នាហ្នឹងម៉ង ឈ្មោះភក្ត្រ័ដែរតែ គេ វង្ស សុភក្ត្រ័ ខ្ញុំឯនេះជាតិ មួយជាតិមួយវង្ស។

កៈ ចាំ!
ចុះបងអើមានចងចាំថាកាលនៅពីក្មេងតើបងមានធ្លាប់ចាំថាបងបានធ្វើអីគេខ្លះជាមួយមិត្តភ័ក្រ្តបងណា? ដូចរត់លេងធ្វើអីៗចឹងណាំបង?

ខៈ នាំគ្នាដើរកើបបាយកើបអីតាមថ្នល់ហ្នឹង។
ដើរកើបបាយកើបអីតាមថ្នល់ហ្នឹងហូបជាមួយគ្នារហូត
ដល់តែពេលបែកគ្នារហូតមកដល់អតឡូវអើម៉ែគេចាប់ទៅខាងនុះវិញយើងឯនេះមកខាងប្រពន្ធ យើងវិញ។

កៈ
ហើយអើខ្ញុំចង់សួរមួយទៀតថាតើបងប្រុសពីមុនធ្លាប់ធ្វើស្រែចម្ការឬក៏ធ្លាប់ធ្វើអាជីវកម្មអីទេបង?

ខៈ ធ្លាប់ធ្វើស្រែចម្ការអើធ្លាប់ដាំស្លឹកគ្រៃ អើដាំល្ពៅ ដាំននោង ត្រសក់អី
និងដើមឈើអីជាដើម ស្រែអីធ្លាប់ច្រូតធ្លាប់ស្ទូង
ធ្លាប់ច្រូតស្ទូងដកសំណាបរែកកណ្តាប់រែកអីហ្នឹងចេះមួយចប់។

កៈ ចាំបង។
ចឹងខ្ញុំចង់សួរបងទៀតថាបន្ទាប់ពីអាជីពទាំងអស់ហ្នឹងតើបងធ្លាប់ធ្វើកិច្ចការងារអ្វីខ្លះទៀតនៅក្នុងជីវិតរបស់បងណា?

ខៈ មានតែរើសអេតចាយហ្នឹងណា ចេញពីផ្ទះឡើងគឺមានតែអេតចាយហ្នឹងមួយមុខគត់។

កៈ ចាំ! ចឹងខ្ញុំចង់សួរបងទៀតថាតាំងពីក្មេងរហូតមកដល់ពេលនេះណា
តើជីវិតរបស់បងណាមានការ ផ្លាស់ប្តូរអីគេខ្លះដែរបង?

ខ៖ ផ្លាស់ប្តូរត្រង់ថាហេតុអ្វីបានយើង ផ្លាស់ប្តូរវែងឆ្ងាយម៉ងហ្នឹងណាក្នុងមួយឆាកជីវិតហ្នឹងក្នុងពីម៉ោង
ពេលថ្ងៃអីចឹងយើងអាចផ្លាស់ប្តូរគំនិតយើងមិនមែននៅដដែលៗទេគឺវាអាចឈានទៅរកការនេះ ការនុះបន្តិចម្តងៗ
ដូចជាពេលនេះចឹងយើងត្រូវគិតថាខិតខំរកមុខរបស់អីដើម្បីអោយបានយក
មកចិញ្ចឹមគ្រួសារ តែបើសិនជាយើងធ្វើការវាដាំខែ វាកំរបានកំរៃមក។

ក៖ ចាំ!

ខ៖ ចុះបើសិនជាយើងមិនរើសអេតចាយអោយបានលុយទេ។

ក៖ ហើយអើបងប្រុសខ្ញុំចង់សួរបងទៀតថា តើបងចូលចិត្តម្ហូបអីគេដែរ?

ខ៖ បើនិយាយទៅស្អីក៏ហូបបានដែរ ដូចជាគ្រឿងអោយតែថាជាតិប្រៃ។

ក៖ ចាំ! ចឹងបងចូលចិត្តម្ហូបអីដែលមានរសជាតិប្រៃមែនទេបង?

ខ៖ បាទ! ហ្នឹងហើយ។

ក៖ ចាំ! ចឹងខ្ញុំចង់សួរបងទៀតថា
តើបងធ្លាប់លេងល្បែងកំសាន្តអីគេខ្លះនៅពីក្មេងណាំដែលបងចូល ចិត្តជាងគេ?

ខ៖ អត់មានស្អីដែលលេងល្បែងស្អីទេ។

ក៖ អត់ទេ! ចឹងនិយាយថា បោះអង្គុញ ចោលឈូកអីចឹងណាំ?

ខ៖ អត់!អត់ធ្លាប់មានប្រវត្តិម៉ង។
បាទគេបបួលម៉េចក៏ដោយក៏អត់ធ្លាប់មានប្រវត្តិលេងជាមួយគេដែរ។

ក៖ ចាំ! ចឹងបងនៅតែផ្ទះរហូតចឹង?

ខ៖ ហ្នឹងហើយ។ នៅតែផ្ទះតែលគោលដូចសត្វឆ្មា សត្វអីចឹងហាហា។

ក៖ ចាំ! ចឹងខ្ញុំចង់សួរបងទៀតថាតើបងចេះច្រៀងចម្រៀងអត់?

ខ៖ ខ្ញុំចេះច្រើនបទណាស់។

ក៖ ចាំ! បងចេះច្រៀងបទអី? បទដែលបងចូលចិត្តណា?

ខ៖ បទពីដើមៗ បទសាមុតគឺចូលចិត្តទាំងអស់ម៉ង។
មនោសញ្ចេតនាបទសាមុតឆ្លងឆ្លើញចេះច្រើន ដែរ។

ក៖ ចាំ! ចឹងបទអីក៏ដោយអោយតែបទស៊ិន ស៊ីសាមុតគឺបងចូលចិត្តទាំងអស់?

ខ៖ ហ្នឹងហើយរស់សេរីសុទ្ធាអីហ្នឹង។ បទអ្នកចម្រៀងពីដើមគឺយើងចងចាំតែម្តង។

ក៖ ចាំ!
ចឹងខ្ញុំចង់សួរបងទៀតថាតើបងមានបងប្អូនដែលគាត់ចេះលេងឧបរកណ៍ភ្លេងអីមួយដែរអត់បង?

ខ៖ អត់។

ក៖ បងប្រុសអត់ចេះដែរ?

ខ៖ អត់ទាំងអស់។ ខ្ញុំអត់ដែលធ្លាប់ទេ តែបើថាចម្រៀងខ្ញុំចាំភ្លេងបាន។

ក៖ ចាំ!
ចឹងខ្ញុំចង់សួរបងទៀតថាតើផ្ទះរបស់បងតាំងពីបងរស់នៅតាំងពីក្មេងរហូតមកដល់ឥឡូវហ្នឹងគឺ មានការផ្លាស់ប្តូរអីគេខ្លះដែរ?

ខ៖ អត់មានផ្លាស់ប្តូរស្អីគេផងហ្នឹង។ មើលទៅ
គឺគ្រួសារយើងគ្មានផ្ទះសម្បែងតែម្តងហ្នឹងណាំ គឺរស់នៅ តាមចិញ្ចើមថ្នល់។
ជួនកាលទៅមានផ្ទះជួលបើមានលុយជួលផ្ទះគេនៅ ក៏នៅទៅមួយខែសាមសិប
ហាសិបអីហ្នឹង។ បើត្រូវគេទារខ្លាំងក៏ទៅពឹងគេខ្ចីលុយគេអីចឹងទៅមួយដងមួយកាលហ្នឹង។
ខ្ចីតែលុយ អោយគេហ្នឹង បើថាយើងរកនេះ។

ក៖ ហើយអើខ្ញុំចង់សួរបងទៀតថាតើបងប្រុសធ្លាប់ចេះសាងសង់ផ្ទះនិងជួលជុលផ្ទះទេបង?

ខ៖ អត់ទេ! ធ្លាប់តែ
ជួលកាលចឹងយើងធ្លាប់នៅខេត្តចឹងគេប្រើអោយជួយដាក់ឈើចេះដាក់ឈើចុះអី
អាហ្នឹងអាចជួយគេបានមែន តែបើថាគេអោយលុយអោយកាក់អីអាហ្នឹងគឺអត់ទេ
អត់មានទេ។

ក៖ ចាំ! ចឹងមានន័យថាបងធ្លាប់ជួយគេសាងសង់ផ្ទះអោយគេខ្លះដែរមែនទេបង?

ខ៖ បាទ! គេអាហ្នឹងរបៀបថាយើងនៅជាមួយគេហ្នឹងគេប្រើយើងហើយ។

ក៖
ហើយចឹងអើខ្ញុំចង់សួបងទៀតថាតើក្រុមគ្រួសាររបស់បងណាមានបន្សល់ទុកនៅជំនាញអីមួយ សម្រាប់បន្តវេនដល់កូនចៅជំនាន់ក្រោយទេបង?

ខ៖ ទេ! ដូចជាអត់មានសល់គេអាករអីទេ។

ក៖ ហើយខ្ញុំចង់សួរទាក់ទងអំពីជីវិតរបស់បងវិញ
តើមានពេលណាខ្លះដែលបងពិបាកជាងគេបំផុតនៅ ក្នុងជីវិតរបស់បងណា៎?

ខ៖ មានពេលលំបាកតែរហូតហ្នឹង តាំងពីមុនរហូតមកដល់ឥឡូវហ្នឹង
ពេលណាស្រណុកទេ លំបាករហូត គ្មានពេលដែលយើងត្រូវសប្បាយកើតទេ
សប្បាយតែពេលយើងមានពេលជជែកលេងកំសាន្តចឹង យើងអាចសើចលេងសប្បាយញញឹមអីបាន។

ក៖ ចា៎!

ខ៖ អាហ្នឹងជាមួយអ្នកដូចជាមកសម្ភាសជាមួយចែងងអីចឹង។
អាហ្នឹងខ្ញុំអាចនិយាយជាមួយបាន
និយាយលេងជាមួយប្រពន្ធអីនិយាយលេងសើចមួយដងមួយកាលបាន
តែបើថាផុតពីហ្នឹងទៅគឺ យើងដេកគិតថាពិបាកហើយ
ព្រោះមិនដឹងថាត្រូវទៅរកស្អីគេទេមុខរបរយើងនុ៎ះ នៅសព្វថ្ងៃហ្នឹង ឥឡូវ។

ក៖ ហើយចឹងខ្ញុំចង់សួរបងថាតើបង
បានឆ្លងកាត់ឧបសគ្គទាំងអស់ហ្នឹងដោយរបៀបណាដែរ?

ខ៖ គឺវាវែងឆ្ងាយតែម្តង ខ្ញុំរៀបរាប់មិនអស់ទេអារឿងចឹងៗ។ ខ្ញុំរៀបរាប់ពុំអស់ទេ
គឺយើងពិបាកតែម្តង និងឧបសគ្គយើងមួយៗគឺរាប់រយពាន់ម៉ឺនឧបសគ្គ។

ក៖ ចា៎! ហើយចឹងខ្ញុំចង់សួរបងប្រុសទៀតថា
តើបងប្រុសធ្លាប់មានបទពិសោធន៍អ្វីខ្លះដែលសប្បាយៗ នៅក្នុងជីវិតរបស់បងអត់?
ដូចជាពេលដែលជួបជុំជាមួយនិងក្រុមគ្រួសារអីចឹងណា៎?

ខ៖
វាម៉្យាងយើងពិបាកក្នុងពេលយើងសប្បាយបានតែម៉ាមើលតាមកំប្លែងគេត្រូវលេងអោយសើច សើចទៅណាកំប្លែង ដូចជា...

ក៖ ដូចជាកំប្លែង ពាក់មីអី?

ខ៖ ហ្នឹងហើយ។ កំប្លែងពាក់មី ដូចជាកំប្លែងក្រុមអាគុយអាអីហ្នឹង។ វាលេងសើចសើចតាម។ យើងចូល រោងការហ្នឹងណា ខ្ញុំអត់ចេះហូបស្រាទេណាខ្ញុំប្រាប់ថៃឯងនេះ ខ្ញុំចេះជក់តែបារីមួយមុខគត់ ហើយ និងកាហ្វេហ្នឹង។ តែអាឡូវលែងផឹកហើយកាហ្វេផឹកតែអានេះហ្នឹងហើយជំពាក់លុយគេទៀត ជំពាក់គេអត់ទាន់អោយលុយគេទៀត។

ក៖ ចា៎! ចុះបងម៉េចមិនព្រមផ្តាច់បារីមួយទៀតទៅបង ព្រោះវាធ្វើអោយយើងសុខភាពមិនសូវល្អណា?

ខ៖ បើផ្តាច់បារីយើងកាន់តែអផ្សុកកាន់តែមែនទែនហើយ ព្រោះយើងអត់ចេះស្អីល្បែងអីគ្រឿងញៀនក៏ អត់មានធ្លាប់ដែរ។

ក៖ ចា៎!

ខ៖ គ្រឿងញៀនយើងអត់ចេះប្រើប្រាស់អីផងហ្នឹង ហើយបើយើងមានតែបារីតែមួយមុខគត់ហ្នឹងដែល យើងត្រូវជក់បន្តកញ្ចប់។ មួយថ្ងៃៗបង្ខំប្រពន្ធចង់ងាប់ទម្រាំតែគ្នារកលុយអោយយើងបាន ទិញបារីមួយកញ្ចប់នុះ រហូតដល់ថ្នាក់ដេញគ្នាអោយរកអោយជក់ហ្នឹង។ កូនអីហ្នឹងជួលកាលដើរសុំ លុយគេដើរលេងនេះលេងនោះឈ្នះតិចតួចអីទៅ ទិញបារីអោយឪពុកជក់ហើយមួយកញ្ចប់អីហ្នឹង ហើយគេទុកតែបួនប្រាំរយដាក់ខ្លួនទេម្នាក់ៗ។

ក៖ ចា៎! ចឹងបានន័យថាគាត់ចេះតស៊ូនៅក្នុងជីវិតរបស់គាត់តាំងតែពីក្មេង?

ខ៖ ហ្នឹងហើយកូនខ្ញុំកូនបងស្រីភ្លូងនេះ។

ក៖ ចា៎!

ខ៖ ជាតិ សុស្រីភួងនេះ និងកូនហ្នឹងគឺឆ្លាតជាងគេហើយ។ កូនស្រីប៉ុណ្ណឹងបើពួកនេះវិញនៅតូចៗហ្នឹងវា មានចេះរកលុយអីវា។ វាអត់ចេះទេចេះតែបងប្អូនវាពីរនាក់ហ្នឹង។ ជួលកាលទៅប្អូន ទៅនោះ ទៅ

យាយវាប្រើទៅអោយលុយទៅហុចចេះទៅបាន យាយវាទាយបានមួយម៉ឺនប្រាំពីរម៉ឺនអីចឹងទៅ។ គាត់អោយមួយពាន់ពីរពាន់អីចឹងទៅ មួយនាក់ណាំ។

កៈ ចាំបង!

ខៈ កូនខ្ញុំនេះឆ្លៀតទិញបារីអោយឪពុកទៅមួយកញ្ចប់ហ្នឹងទៅអោយជក់។ វាទុកតែមួយនាក់បួនប្រាំរយ មួយពាន់អីចឹងទៅ។ វាផ្គុំគ្នា ដល់តែពេលយើងឯនេះរៀបអេតចាយអីចឹងទៅ។ យើងអត់មានលុយ បានមកជូនកាលលក់បានមួយម៉ឺនជាងពីរម៉ឺនអីហ្នឹងនៅក្នុងមួយយប់ៗ។

កៈ ចាំ! ចឹងខ្ញុំចង់សួរបងប្រុសទៀតថាតើនៅពីក្មេងរហូតមកដល់ពេលឥឡូវ តើបងធ្លាប់មានសង្ឃឹម ចង់បានអី? ហើយចង់ធ្វើអីគេដែរបង?

ខៈ អើខ្ញុំភាគច្រើនខ្ញុំមិនដឹងខ្លួនខ្ញុំចង់ធ្វើស្អីលក់ស្អីទេ រកស៊ីអីទេមិនដែលគិតទេ គិតថាក្រៅពី អេត ចាយមួយមុខ ឆាប់បានលុយរហ័សជាងគេគឺអេតចាយហ្នឹងហើយ។ មុខរបរអត់ដើមន គឺប្រើបាទ ដៃទទេហ្នឹងហើយ។ ក្តីសង្ឃឹមនៅក្នុងជីវិតយើងគឺមានតែអេតចាយហ្នឹងហើយ ដែលយើងរកស៊ីអត់ ដើម ចឹងយើងអាចដើររើសបាន។

កៈ ចាំ! ចឹងខ្ញុំចង់សួរបងទៀតថាបើសិនជាបងអាចផ្តែផ្តាំពាក្យពេចន៍អីមួយទៅកាន់កូនចៅជំនាន់ក្រោយរបស់បងណានៅពេលដែលគាត់ធំឡើងណាំ តើបងមានបំណងចង់អោយគាត់ក្លាយទៅជា ក្មេងរបៀបណា?

ខៈ ចឹងថាចែកបើទោះថាធំឡើងយើង ឪពុក មុននឹងឪពុកក្រោយបិទភ្នែកចោលកូនសុំផ្តែរផ្តាំថា សុំ អោយកូនស្រីកូនប្រុសក៏ដោយស្តាប់ឪពុកធំឡើងបើសិនជាមានប្តីមានប្រពន្ធក៏ដោយកុំចេះឈ្លោះគ្នាដូចជាឪពុកជេរម៉ែកូនចឹងណាំ ធ្វើឡប់ៗឆ្កួតៗនៅមុខកូនចឹងកុំអោយសោះកូន យកប្រើ យក អោយល្អ តស៊ូរកប្តីណាអោយមាន រកប្រពន្ធណាអោយចេះស្មាត់ ទោះថាមិនចេះអក្សរអោយមាន ចំណេះ។

កៈ ចាំ! ចឹងអរគុណច្រើនបង។ ហើយចឹងជាចុងក្រោយខ្ញុំអរគុណបងដែលបងបានផ្តល់ការពិភាក្សាមួយហ្នឹងសម្រាប់ខ្ញុំ

ហើយពីមុន
ពេលចប់ហ្នឹងខ្ញុំអាចសូមថតរូបបងជាមួយនិងគ្រួសាររបស់បងទុកជាអនុស្សាវរីយ៍បានទេបង?

ខ៖ បានតើ។

ក៖ អរគុណបង។